**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

តុលាការក្រុងព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៣ ចុះថ្ងៃទី ១៧
ខែ មករា ឆ្នាំ ២០០៤
សាលក្រម
លេខ ៣៥ ចុះថ្ងៃទី ០២
ខែ មិថុនា ឆ្នាំ ២០០៤

---

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃ រដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

**មេធាវី**

លោក [redacted]ជុនធី

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះខាងក្រោមនេះ :

១-ឈ្មោះ **ព សខ** ហៅ **ខណ** ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រោលគោ ឃុំក្រោលគោ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីកម្មករនេសាទ ប្រពន្ធឈ្មោះ **ញ ៩** ឪពុកឈ្មោះ **ព ន** (ស) ម្តាយឈ្មោះ **ព ទ** (ស) ទោសពីមុន *គ្មាន* ។ ចាប់ខ្លួនថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៤ ។

ត្រូវចោទពីបទ **"រំលោភលើសេចក្តីទុកចិត្ត"** ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ១ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែ មីនា ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ស ខ** ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុម ១២ ភូមិ ២ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ី រត់ម៉ូតូឌុប ជាដើមបណ្តឹង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១២៩ ដ.ស.ព ០៤ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៤០៨ ត.ព ០៤ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០២ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ,ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
ក្រឡាបញ្ជី
[redacted]

CamScanner

## ឯរឿងហេតុមានដូចតទៅ :

កាលពីខែ មីនា ឆ្នាំ ២០០៣ ឈ្មោះ ព **សទ** បានខ្ចីម៉ូតូសេ ១០០ ពណ៌ខ្មៅ ពីជនរងគ្រោះឈ្មោះ **ស ខ** ដើម្បីយកបង្ហាទៅអោយបងប្អូននៅភូមិថ្មីមួយភ្លែតឈ្មោះ **ស ខ** បានអោយម៉ូតូទៅឈ្មោះ ព សទ បន្ទាប់ពីបានម៉ូតូក៏យកទៅបាត់រហូត លុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤ ទើបសមត្ថកិច្ចចាប់ឃាត់បាន ។

## នាពេលសវនាការ

-ឈ្មោះ ព **សទ** ជាជនជាប់ចោទបានឆ្លើយថា : ខ្លួន និង ឈ្មោះ ស ខ ជាមនុស្សធ្លាប់ស្គាល់គ្នា មុនពេលកើតហេតុប្រហែល ០៣ខែកន្លងមកហើយខ្លួនធ្លាប់ខ្ចីម៉ូតូឈ្មោះ ខ ជិះប្រហែល ៥ដង មកហើយ ។ លុះនៅថ្ងៃកើតហេតុថ្ងៃខែមិនចាំ ឆ្នាំ ២០០៣ ខ្លួនបានខ្ចីម៉ូតូពីឈ្មោះ **ស ខ** នៅផែដីខ្សាច់ថា យកបង្ហាទៅអោយបងធម៌នៅភូមិថ្មី ។ ពេលខ្លួនទៅដល់ផ្ទះបងធម៌នៅភូមិថ្មី ហើយជាប់មាត់និយាយគ្នាជាមួយបងធម៌ ខ្លួនក៏អោយឈ្មោះ ស ដែលជាកូនដៃទូកធ្លាប់នៅជាមួយគ្នា ថៅកែជាមួយគ្នាទៀតផង យកម៉ូតូទៅអោយឈ្មោះ ស ខ ផង ពីព្រោះខ្លួចគាត់ចាំយូរ ។ លុះរំលងបាន ០១យប់ស្រាប់តែគេនិយាយថា ខ្លួនបោកម៉ូតូគេ ពេលនោះខ្លួនក៏ចុះទូកទៅកោះកុងទៅរកស៊ីយកលុយមកសងគេវិញពុំទាន់បានបើកលុយពីថៅកែផង ស្រាប់តែសមត្ថកិច្ចចាប់ខ្លួន និង ឃុំខ្លួនរហូតមកដល់សព្វថ្ងៃនេះ ឯឈ្មោះ ស ខ្លួនពុំដឹងថាឈ្មោះនេះនៅទីណាទេ ។

-តាមការអានចម្លើយរបស់ឈ្មោះ **ស ខ** ជាដើមបណ្តឹង និង ជាជនរងគ្រោះបានឆ្លើយថា : កាលពីមុនកើតហេតុឈ្មោះ ព **សទ** ធ្លាប់ជិះម៉ូតូឌុបខ្លួនជាញឹកញាប់ ជួនកាលឈ្មោះនេះធ្លាប់ជួលរបស់ខ្លួនជិះចំនួន ០២លើកមកហើយ ហើយបានយកម៉ូតូមកអោយខ្លួនវិញជាធម្មតា ។

-លុះលើកទី ៣ នៅក្នុងអំឡុងខែ មីនា ឆ្នាំ ២០០៣ ឈ្មោះ ព **សទ** បានជួលម៉ូតូខ្លួនជិះម្តងទៀត គេនិយាយថាជិះទៅភូមិថ្មីក្នុងតម្លៃ ២.០០០ រៀល ។ ចាប់ពីពេលជួលតាំងពីម៉ោង ៩:០០ព្រឹករហូតដល់យប់ពុំឃើញឈ្មោះ ព **សទ** យកម៉ូតូមកឱ្យវិញ លុះក្រោយមកនៅខែ មករា ឆ្នាំ **២០០៤** ខ្លួនបានឃើញឈ្មោះ ព **សទ** កំពុងលេងបុកប៊ីយ៉ានៅអូរវៀតណាម ខ្លួនក៏ប្តឹងសមត្ថកិច្ចចាប់ខ្លួនឈ្មោះ ព **សទ** តែម្តងទៅ ។ នៅក្នុងរឿងនេះសុំអោយជនជាប់ចោទសងប្រាក់ថ្លៃម៉ូតូចំនួន ២៣០ដុល្លាមកខ្លួន និង សុំអោយតុលាការបន្ធូរបន្ថយទោសឈ្មោះ ព **សទ** ដោយអនុគ្រោះ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ព **សទ** ហៅ **ខណ** ពីបទរំលោភសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិ៣ សង្កាត់១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែ មីនា ឆ្នាំ ២០០៣ ។

បទល្មើសពហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហេតុដូច្នេះសុំឱ្យចៅក្រមវិនិច្ឆ័យទៅតាមច្បាប់ដោយអនុគ្រោះ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនពិតមែនតែបានជួលម៉ូតូរបស់ដើមបណ្តឹង តែគាត់មិនបានយកទៅណាទេ តែដោយគាត់ជាប់រវល់ជួបបងប្អូនក៏បានប្រគល់ម៉ូតូរបស់ដើមបណ្តឹងនេះអោយទៅឈ្មោះ **ស** ដែលធ្លាប់ចុះទូកយន្តជាមួយគ្នាក្នុងផ្ទះថៅកែតែមួយ តែកន្លងមកចៅក្រមស៊ើបអង្កេតមិនបានស៊ើបអង្កេតឃើញឈ្មោះ **ស** អ្វីដែរ ថាតើឈ្មោះ **ស** យកម៉ូតូមែនដែរឬអត់ ? តែបើតាមចម្លើយរបស់កូនក្តីខ្លួន ថាឈ្មោះ **ស** បានចាកចេញពីកម្មករទូកមិនដឹងទៅរស់នៅឯណាទេ ដូច្នេះឈ្មោះ **ស** ពិតជាបានយកម៉ូតូរបស់ដើមបណ្តឹង រឿងអ្វីបានជាចាកចេញពីលំនៅដ្ឋានដែលកំពុងតែមានមុខរបរផងនោះ ដោយទុកកូនក្តីខ្លួននៅជាប់ក្នុងគុក ដូច្នេះតុលាការគួរតែចាត់ការស៊ើបសួរឈ្មោះ **ស** ឬថៅកែឈ្មោះ **ស** បន្ថែមទៀត ដើម្បីអោយមានភាពយុត្តិធម៌សំរាប់កូនក្តីខ្លួន ។ តែបើតុលាការយល់ឃើញថា កូនក្តីខ្លួនជាប់ពាក់ព័ន្ធមែន សុំតុលាការអនុគ្រោះគ្រាប្រណីកូនក្តីខ្លួនដោយអនុគ្រោះផងចុះ ។

CamScanner

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការអានចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**តុលាការក្រុងព្រះសីហនុ**

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-ឈ្មោះ ព **សខ** ពិតជាបានជួលម៉ូតូកូរ៉េរបស់ឈ្មោះ **ស ខ** កាលពីអំឡុងខែ មីនា ឆ្នាំ ២០០៣ យកទៅជិះ ហើយគេចខ្លួនបាត់រហូត ដល់ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤ ទើបសមត្ថកិច្ចចាប់ខ្លួនបាន ។

-តាមចម្លើយរបស់ឈ្មោះ **ស ខ** ជាដើមបណ្តឹងឆ្លើយថា ឈ្មោះ **ព សខ** បានជួលម៉ូតូរបស់ខ្លួនជិះកាលពី ខែ មីនា ឆ្នាំ ២០០៣ ហើយយកទៅបាត់រហូត លុះដល់ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤ ទើបឃើញឈ្មោះ **ព សខ** កំពុងលេងបុកប៊ីយ៉ានៅអូរវៀតណាម ខ្លួនក៏ប្តឹងសមត្ថកិច្ចអោយចាប់ខ្លួនឈ្មោះ **ព សខ** តែម្តងទៅ ។

-តាមការអះអាងរបស់ជនជាប់ចោទ បានបញ្ជាក់ថា ខ្លួនគេពិតជាបានជួលម៉ូតូរបស់ឈ្មោះ **ស ខ** មែនតែ ដោយខ្លួនជាប់រវល់ជួបបងប្អូនមិនបានយកម៉ូតូមកអោយឈ្មោះ **ស ខ** វិញក៏ប្រគល់អោយឈ្មោះ **ស** ជាអ្នកយកទៅ អោយ **ស ខ** ដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវពីការបាត់បង់ម៉ូតូនេះដែរ ។

-បណ្តឹងទាមទារសំណងថ្លៃម៉ូតូរបស់ដើមបណ្តឹងមានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការពិនិត្យ ពិចារណា ដល់បញ្ហានេះ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ព សខ** ហៅ **ខណ** ពីបទរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែ មីនា ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ**

**សំរេច :**

**ផ្តន្ទាទោស :**

១-ឈ្មោះ **ព សខ** ហៅ **ខណ** ភេទប្រុស អាយុ**២៧** ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤ ។

ពីបទរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីខែ មីនា ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-អោយឈ្មោះ **ព សខ** សងម៉ូតូម៉ាកសេ ១០០ កូរ៉េ ០១គ្រឿង តម្លៃម៉ូតូចំនួន ៥០០.០០០រៀល ( ប្រាំរយពាន់រៀលគត់) ទៅឈ្មោះ **ស ខ** ជាដើមបណ្តឹង ចាប់តាំងពីសាលក្រមនេះចូលជាស្ថាពរ ។ សំណើលើសពីនេះបដិសេធចោល ។

CamScanner

ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ និង ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹង បើកផ្លូវប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]

CamScanner